ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១៦-០០៤ ធ.ក.ជ.ប.ស

# សារាចរណែនាំ
# ស្តីពី
# ការពង្រឹងការអនុវត្តច្បាប់
# ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់

ដើម្បីអនុវត្តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ឲ្យបានម៉ឺងម៉ាត់និងពេញលេញ ធានាបាននូវប្រសិទ្ធភាពនៃការទូទាត់ បង្កើនភាពជឿជាក់លើឧបករណ៍ទូទាត់ ការពារផលប្រយោជន៍អ្នកទទួលផល ព្រមទាំងដើម្បីកាត់បន្ថយឲ្យបានជាអតិបរមានូវបរិមាណមូលប្បទានប័ត្របង្វិលវិញ ធនាគារជាតិនៃកម្ពុជាសូមណែនាំដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ ដូចតទៅះ

- ផ្សព្វផ្សាយដល់បុគ្គលិកនូវច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ជាពិសេសមាត្រានានាដែលពាក់ព័ន្ធនឹងការចេញផ្សាយ ការប្រើប្រាស់ ការទូទាត់មូលប្បទានប័ត្រ និងក្រើនរំលឹកបុគ្គលិកដែលមានភារកិច្ចពាក់ព័ន្ធឲ្យយកចិត្តទុកដាក់ពិនិត្យដោយប្រុងប្រយ័ត្នអំពីភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃនិទ្ទេសលើមូលប្បទានប័ត្រ។
- ណែនាំអតិថិជនឲ្យបានយល់ច្បាស់អំពីល័ក្ខខ័ណ្ឌ នីតិវិធីនៃនៃការចេញផ្សាយ និងការប្រើប្រាស់មូលប្បទានប័ត្រ។ មូលប្បទានប័ត្រត្រូវតែទូទាត់សងនៅពេលបង្ហាញ ទោះបីជាមូលប្បទានប័ត្រនោះបង្ហាញនៅមុនកាលបរិច្ឆេទចេញផ្សាយក៏ដោយ។
- ធនាគារបហារិតត្រូវកត់ត្រាហេតុការណ៍ និងរាយការណ៍អំពីមូលប្បទានប័ត្របង្វិលវិញដោយសារមូលនិធិមិនគ្រប់គ្រាន់មកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល២ថ្ងៃបន្ទាប់ ដើម្បីធនាគារជាតិនៃកម្ពុជាអនុវត្តសិទ្ធិផ្តន្ទាទោសខាងវិន័យ ដូចមានចែងក្នុងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ករណីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់មិនបានអនុវត្តឲ្យបានម៉ឺងម៉ាត់នូវសារាចរណែនាំនេះ ព្រមទាំងវិធាន និងនីតិវិធីពាក់ព័ន្ធនឹងឧបករណ៍ទូទាត់ និងប្រតិបត្តិការទូទាត់សងប្រាក់ នឹងត្រូវទទួលរងនូវការពិន័យដូចមានចែងក្នុងច្បាប់ បទប្បញ្ញត្តិមួយចំនួនជាធរមាន។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៚

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦

**ទេសាភិបាល**

**ជា.ចាន់តូ**